ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សម្ព័ន្ធចាប់ដៃ
CHAB DAI
COALITION

# អនុស្សរណៈនៃការយោគយល់គ្នា

## រវាង

## អង្គការសម្ព័ន្ធចាប់ដៃ (CHAB DAI COALITION)

## ដែលរួមសហប្រតិបត្តិការអនុវត្តគម្រោងជាមួយអង្គការដៃគូអភិវឌ្ឍន៍

## អេរិក្ស (ERIKS Development Partner)

## និង

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## ស្តីពី

## ការចូលរួមសកម្មភាព បង្ការទប់ស្កាត់ អំពើជួញដូរកុមារ ការកេងប្រវ័ញ្ចផ្សេងៗ និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ

២០១៩ - ២០២៤

# សង្ខេបគម្រោង

| | |
|---|---|
| **ឈ្មោះអង្គការ៖** | អង្គការសម្ព័ន្ធចាប់ដៃ (CHAB DAI COALITION) |
| **ប្រភេទអង្គការ៖** | អង្គការបរទេស |
| **អាសយដ្ឋាន៖** | ផ្ទះលេខ១៦៣ ផ្លូវលេខ២៧BT សង្កាត់បឹងទំពុន១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| **លេខទូរស័ព្ទទំនាក់ទំនង៖** | (៨៥៥) ១២ ៤៨១ ៥៩៧, (៨៥៥) ១២ ៤៩៩ ២០២ |
| **អ៊ីម៉ែល៖** | ros.yeng@chabdai.org |
| **ឈ្មោះគម្រោងសកម្មភាព៖** | ប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានផ្លូវភេទ និងការជួញដូរមនុស្ស |
| **លេខកូដគម្រោង៖** | គ្មាន |
| **ទីតាំងគម្រោង៖** | ២៥ រាជធានី ខេត្ត |
| **ដៃគូអនុវត្តគម្រោង៖** | អង្គការដៃគូអភិវឌ្ឍន៍ អេរិក្ស (ERIKS Development Partner) |
| **ថវិកាអនុវត្តគម្រោង៖** | **5,114,219.00** ដុល្លារអាមេរិក |
| **កាលបរិច្ឆេទចាប់ផ្តើម៖** | ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៩ |
| **កាលបរិច្ឆេទបញ្ចប់៖** | ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២៤ |
| **ចំនួនបុគ្គលិកខ្មែរ៖** | ៥២ នាក់ (ស្រី 29 នាក់) |
| **ចំនួនបុគ្គលិកបរទេស៖** | ០១ នាក់ |
| **អ្នកគ្រប់គ្រងគម្រោង៖** | រស់ យ៉េង |

## អនុស្សរណៈនៃការយោគយល់គ្នា

## រវាង

## អង្គការសម្ព័ន្ធចាប់ដៃ (CHAB DAI COALITION)

## ដែលរួមសហប្រតិបត្តិការអនុវត្តគម្រោងជាមួយអង្គការដៃគូអភិវឌ្ឍន៍

## អេរិក្ស (ERIKS Development Partner)

## និង

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## ស្តីពី

## ការចូលរួមសកម្មភាព បង្ការទប់ស្កាត់ អំពើជួញដូរកុមារ ការកេងប្រវ័ញ្ចផ្សេងៗ និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ

## បុព្វកថា

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសំដែងនូវបំណងប្រាថ្នាដូចមានចែងក្នុងអនុស្សរណៈ នៃការយោគយល់គ្នានេះថា អង្គការសម្ព័ន្ធចាប់ដៃ ដែលបាន និងកំពុងរួមសហប្រតិបត្តិការអនុវត្តគម្រោងជាមួយ អង្គការដៃគូអភិវឌ្ឍន៍ អេរិក្ស បានរួមធ្វើការងារមនុស្សធម៌ដើម្បីសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈតាមរយៈកិច្ចសហប្រតិបត្តិការទៅវិញទៅមកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ដោយហេតុថា៖** អង្គការសម្ព័ន្ធចាប់ដៃ ដែលបាន និងកំពុងរួមសហប្រតិបត្តិការអនុវត្តគម្រោងជាមួយ អង្គការដៃគូអភិវឌ្ឍន៍ អេរិក្ស និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវសហការគ្នាប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស រាល់ទម្រង់នៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ។

**ដោយហេតុថា៖** ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាល់ទម្រង់នៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ អង្គការសម្ព័ន្ធចាប់ដៃ ដែលបាន និងកំពុងរួមសហប្រតិបត្តិការអនុវត្តគម្រោងជាមួយ អង្គការដៃគូអភិវឌ្ឍន៍ អេរិក្ស និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា សហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនព្រមទាំងការិយាល័យរាជធានី-ខេត្ត ដើម្បីបន្តចូលរួមក្នុងសកម្មភាពមនុស្សធម៌ដូចខាងក្រោម៖

# ផ្នែកទី១

## សកម្មភាពអនុវត្តរបស់អង្គការសម្ព័ន្ធចាប់ដៃ (CHAB DAI COALITION)និង អង្គការអភិវឌ្ឍ ដៃគូ អេរិក្ស (ERIKS Development Partner)មានសកម្មភាពដូចខាងក្រោម៖

**១) កម្មវិធីសម្ព័ន្ធ៖**

- ✓ ជួយពង្រឹងជំនាញបច្ចេកទេសការគ្រប់គ្រង និងភាពជាអ្នកដឹកនាំដល់អង្គការជាសមាជិករបស់អង្គការសម្ព័ន្ធចាប់ដៃ ដែលបាន និងកំពុងសហប្រតិបត្តិការអនុវត្តគម្រោងជាមួយ អង្គការអេរិក្ស និងគាំទ្របុគ្គលិក រួមទាំងមន្ត្រីពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល ដើម្បីការពារកុមារនៅក្នុងសហគមន៍ ផ្អែកទៅលើការអនុវត្តគោលនយោបាយការពារកុមារ។
- ✓ ផ្តល់ប្រភពព័ត៌មាន និងចំណេះដឹងទូលំទូលាយទៅលើប្រធានបទផ្សេងៗ ស្តីអំពីការសិក្សាទៅលើការថែទាំ និងការធ្វើសមាហរណកម្មរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទដល់អង្គការជាសមាជិកសម្ព័ន្ធចាប់ដៃដែលបាន និងកំពុងសហប្រតិបត្តិការអនុវត្តគម្រោងជាមួយ អង្គការអេរិក្ស តាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាល និងបណ្ណាល័យរបស់ អង្គការសម្ព័ន្ធចាប់ដៃ និង អង្គការ អេរិក្ស។
- ✓ ស្វែងរកការគាំទ្រមតិ បង្កើតអោយមានគំនិតផ្តួចផ្តើមអំពីការជួយដល់ស្ត្រី និងកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ និងសហគមន៍របស់ពួកគេ ឱ្យទទួលបានចំណេះដឹងទូលំទូលាយស្តីពីគ្រោះថ្នាក់នៃអំពើជួញដូរ ការរំលោភបំពានផ្សេងៗ ព្រមទាំងទទួលបានការគាំទ្រយកចិត្តទុកដាក់ពីគ្រួសារឲ្យបានសមស្រប។

**២) កម្មវិធីផ្តល់ការគាំទ្រផ្នែកយុត្តិធម៌ និងសេវាគាំទ្រជនរងគ្រោះតាមសហគមន៍៖**

- ✓ ផ្តល់លេខទូរស័ព្ទទាន់ហេតុការណ៍ (hotline) ដើម្បីរាយការណ៍ពីករណីជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ។ អន្តរាគមន៍ដើម្បីជួយជនរងគ្រោះ និងផ្តល់សេវាផ្សេងៗ ដោយមានការសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន មន្ត្រីជំនាញសង្គមកិច្ច កិច្ចការនារី និងសមត្ថកិច្ច។
- ✓ សហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថានទូតនានា អង្គការអន្តរជាតិ និងអ្នកដែលពាក់ព័ន្ធដើម្បីអន្តរាគមន៍ជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- ✓ ជួយគាំទ្រដល់ជនរងគ្រោះដោយការជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ អោយបានជាសះស្បើយពីការប៉ះទង្គិចផ្លូវចិត្ត និងមានទំនាក់ទំនងល្អជាមួយគ្រួសារ និងសហគមន៍តាមរយៈការផ្តល់ប្រឹក្សាយោបល់ ឧបត្ថម្ភតម្រូវការចាំបាច់ និងពង្រឹងសមត្ថភាពដល់អ្នកផ្តល់សេវាចិត្តសង្គម។

- ✓ ផ្តល់ប្រឹក្សាយោបល់/សេវាផ្លូវច្បាប់ដល់អតិថិជនដើម្បីទាមទារយុត្តិធម៌ និងសំណង។

**៣) កម្មវិធីទប់ស្កាត់៖**

- ✓ សហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីផលិតសម្ភារផ្សេងៗ សម្រាប់អប់រំផ្សព្វផ្សាយ។
- ✓ ពង្រឹងសមត្ថភាពដល់អាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិស្តីពីការទប់ស្កាត់ និងការបង្ការទៅលើអំពើជួញដូរមនុស្ស រាល់ទម្រង់នៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ។
- ✓ សហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីលើកកម្ពស់ការយល់ដឹងទៅដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- ✓ លើកកម្ពស់ការយល់ដឹងទៅដល់ប្រជាពលរដ្ឋក្នុងសហគមន៍ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងឧត្សាសនសព្វ។

**៤) កម្មវិធីស្រាវជ្រាវរយៈពេលវែងរបស់ក្រុមមេអំបៅ៖**

- ✓ ផ្តល់ឱកាសដល់ជនដែលឆ្លងកាត់ពីការរំលោភបំពាន/ការជួញដូរមនុស្ស ដើម្បីបង្ហាញពីទស្សនៈផ្ទាល់ខ្លួន របស់ពួកគេអំពីស្ថានភាពជាក់ស្តែង និងការធ្វើសមាហរណកម្ម តាមរយៈការចូលរួមក្នុងការសិក្សាស្រាវជ្រាវរយៈពេលវែងដើម្បីផ្តល់បទពិសោធន៍ដល់ក្រុមដែលងាយរងគ្រោះ។
- ✓ បង្ហាញពីទស្សនៈផ្ទាល់ខ្លួន និងបទពិសោធន៍របស់ជនដែលរួចផុតពីការរំលោភបំពាន/ការជួញដូរមនុស្ស ទៅដល់អង្គការដែលជាដៃគូរបស់គម្រោងស្រាវជ្រាវមេអំបៅ និងអ្នកដែលធ្វើការពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដទៃទៀតនៅក្នុងប្រទេសកម្ពុជា ដើម្បីបង្ហាញពួកគេឱ្យពួកគេយល់នូវទស្សនៈ និងបទពិសោធន៍របស់ជនដែលរួចពីការរងគ្រោះដោយអំពើជួញដូរមនុស្ស។
- ✓ ផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ និងមេរៀនដែលទទួលបានទៅដល់ក្រុមអ្នកអនុវត្តការងារ អ្នកបង្កើតគោលនយោបាយ និងអ្នកសិក្សាស្រាវជ្រាវទាំងនៅក្នុងតំបន់ និងសកលលោកដែលមានការព្រួយបារម្ភ និងចង់ដោះស្រាយបញ្ហារបស់ជនរួចពីការរងគ្រោះក្រោយពេលធ្វើសមាហរណកម្ម។

## ផ្នែកទី២

## ភាគព្វកិច្ចរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

**មាត្រា១៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គាំទ្របេសកកម្ម អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូបំពេញការងាររបស់ខ្លួនដោយអនុវត្តស្របទៅតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៖** សម្របសម្រួលជាមួយ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត ថ្នាក់ក្រោមជាតិ ដើម្បីចូលរួមសហការសកម្មភាពនានារបស់ អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូ ដើម្បីសម្រេចលទ្ធផលដូចមានចែងខាងលើ។

**មាត្រា៣៖** ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយរាជធានី-ខេត្តពាក់ព័ន្ធ ដើម្បីសម្របសម្រួលអ្នកពាក់ព័ន្ធក្នុងការចូលរួមសកម្មភាព បង្ការទប់ស្កាត់អំពើជួញដូរកុមារ ការកេងប្រវ័ញ្ចផ្សេងៗ និងការរំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ។

**មាត្រា៤៖** ចែករំលែកនូវព័ត៌មាន និងបទពិសោធន៍ល្អ និងលទ្ធផលសម្រេចបាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជាផលប្រយោជន៍នៃការទំនាក់ទំនងនិងលើកស្ទួយប្រសិទ្ធភាពការងារក្នុងការទប់ស្កាត់ ការការពារ និងសមាហរណកម្មអ្នកចំណាកស្រុកដែលងាយរងគ្រោះ និងកុមារដែលត្រូវបានគេជួញដូរ។

## ផ្នែកទី៣

## ភារកិច្ចរបស់អង្គការសម្ព័ន្ធចាប់ដៃ

**មាត្រា៥៖** សម្របសម្រួលជាមួយស្ថាប័ន និងអ្នកពាក់ព័ន្ធសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍន៍ អេរិក្ស ក្នុងសកម្មភាពទប់ស្កាត់ចំណាកស្រុក និងការធ្វើទេសន្តរប្រវេសន៍ខុសច្បាប់ ការជួញដូរមនុស្ស ការរំលោភបំពានផ្សេងៗ និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ។

**មាត្រា៦៖** សម្របសម្រួល និងជំរុញកិច្ចសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍន៍ អេរិក្ស ក្នុងសកម្មភាពបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់នគរបាលមូលដ្ឋាន។

**មាត្រា៧៖** សម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធជួយគាំទ្រ និងសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍន៍ អេរិក្ស ក្នុងការអប់រំផ្សព្វផ្សាយដើម្បីបង្ការទប់ស្កាត់ ការជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការអំពើធ្វើអាជីវកម្មផ្លូវភេទ ការរំលោភបំពានផ្សេងៗ និងការធ្វើទេសន្តរប្រវេសន៍មិនស្របច្បាប់ ។

**មាត្រា៨៖** ក្នុងករណីចាំបាច់ និងតម្រូវការគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍន៍ អេរិក្ស នឹងធ្វើការផ្តល់វគ្គបណ្តុះបណ្តាលដល់ជនបង្គោលក្នុងសហគមន៍ដែលជាអាជ្ញាធរមូលដ្ឋានថ្នាក់ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ភូមិ ព្រមទាំងសមត្ថកិច្ចនគរបាលដែលពាក់ព័ន្ធផ្សេងទៀត។ ប្រធានបទនៃការបណ្តុះបណ្តាលរួមមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការចំណាកស្រុកស្របច្បាប់ និងសិទ្ធិកុមារ។

**មាត្រា៩៖** សម្របសម្រួលអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធជួយគាំទ្រ និងសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍន៍ អេរិក្ស នឹងធ្វើការផ្តល់វគ្គបណ្តុះបណ្តាលដល់ក្រុមគ្រួសារ និង

ប្រជាជននៅក្នុងសហគមន៍ដើម្បីលើកកម្ពស់ការយល់ដឹង ស្តីពីការទប់ស្កាត់ការចំណាកស្រុកខុសច្បាប់ ការជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**មាត្រា១០៖** សម្របសម្រួលជាមួយស្ថាប័នជំនាញ និងសមត្ថកិច្ចពាក់ព័ន្ធឱ្យមានកិច្ចសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍន៍ អេរិក្យ នឹងធ្វើការទៅលើការអន្តរាគមន៍ជួយទៅដល់ជនរងគ្រោះ ករណីជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការរំលោភបំពានផ្សេងៗ។

**មាត្រា១១៖** អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍន៍ អេរិក្យ ត្រូវគោរពអោយបានខ្ជាប់ខ្ជួននូវច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងមិនត្រូវអនុញ្ញាតអោយភ្នាក់ងាររបស់ខ្លួនមានការចូលរួមនូវរាល់សកម្មភាពដទៃទៀត ដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជាឡើយ។

**មាត្រា១២៖** អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍន៍ អេរិក្យ ត្រូវប្រតិបត្តិនូវរាល់សកម្មភាព និងអនុវត្តនូវកម្មវិធីមនុស្សធម៌នៅក្នុងប្រទេសកម្ពុជាដោយផ្អែកទៅតាមធនធានមនុស្ស និងដែនកំណត់នៃមូលនិធិរបស់ខ្លួន។ រាល់សកម្មភាពរបស់ខ្លួនត្រូវរាយការណ៍ និងសហការជាមួយសមត្ថកិច្ចជំនាញ ឬនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្នុងការប្រមូលព័ត៌មានស៊ើបអង្កេតករណីត្រូវមានការឯកភាពគ្នារវាងភាគីទាំងពីរជាមុនសិនមុនពេលអនុវត្ត។

**មាត្រា១៣៖** អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍន៍ អេរិក្យ ប្រកាន់ជំហរអព្យាក្រឹត្យមិនលម្អៀង និងចូលរួមតែក្នុងសកម្មភាពមនុស្សធម៌ ដែលបានទទួលការអនុញ្ញាតពីក្រសួងមហាផ្ទៃ ដើម្បីសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះ ចៀសវាងដាច់ខាតសកម្មភាពដើម្បីរកប្រាក់ចំណេញ និងសកម្មភាពនយោបាយ ដែលមិនបម្រើដល់គោលដៅមនុស្សធម៌ ។

**មាត្រា១៤៖** អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍ អេរិក្យ ត្រូវរក្សាការសម្ងាត់នូវព័ត៌មានដែលទទួលស្គាល់ក្នុងស្មារតី នៃកិច្ចព្រៀងនេះដោយផ្អែកទៅតាមច្បាប់ជាតិ។ អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍន៍ អេរិក្យ ត្រូវធានាដល់ការការពារចំពោះព័ត៌មានសម្ងាត់ពីការចូលមើល ឬស្តាប់ ការកែប្រែ ការបោះពុម្ពផ្សាយ ឬការចែកចាយដែលមិនមានការអនុញ្ញាតដោយយោងទៅតាមច្បាប់ជាតិ។

**មាត្រា១៥៖** អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការដៃគូអភិវឌ្ឍន៍ អេរិក្យ ត្រូវផ្តល់របាយការណ៍សកម្មភាពការងារសមិទ្ធិផល និងបញ្ហាប្រឈមនានាដែលបានជួបប្រទះ ប្រចាំត្រីមាស ឆមាស ឆ្នាំ ជូនមកគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ផ្នែកទី៤

## អវសានបញ្ញត្តិ

**មាត្រា១៦៖** រាល់វិវាទដែលកើតឡើងពីការបកស្រាយ ឬការអនុវត្តន៍ នៃកិច្ចព្រមព្រៀងអនុស្សរណៈនេះនឹងត្រូវដោះស្រាយតាមរយៈការចរចារដោយសន្តិវិធី និងប្រឹក្សាដោយការយោគយល់គ្នារវាង គណៈ

កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការអភិវឌ្ឍដៃគូ ផ្សេងៗ។ កិច្ចព្រមព្រៀងនេះនឹងអាចត្រូវបានត្រួតពិនិត្យ ឬធ្វើវិសោធនកម្មឡើងវិញគ្រប់ពេលដោយមានការយល់ព្រមពី ភាគីទាំងសងខាងជាលាយលក្ខណ៍អក្សរ។

**មាត្រា១៧៖** អនុស្សរណៈនៃការយោគយល់គ្នានេះ អាចត្រូវបញ្ឈប់ដោយភាគីណាមួយក៏បាន គឺបន្ទាប់ពី ៦០ថ្ងៃ ដែលភាគីនោះបានផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបញ្ជូនទៅភាគីម្ខាងទៀត។

**មាត្រា១៨៖** អនុស្សរណៈនៃការយោគយល់គ្នានេះចូលជាធរមាន និងមានសុពលភាពរយៈពេលប្រាំ(០៥)ឆ្នាំ ចាប់ពីកាលបរិច្ឆេទ នៃការចុះហត្ថលេខារបស់ភាគីទាំងពីរនេះតទៅ ហើយអាចនឹងបន្តសាជាថ្មី ប្រសិនបើមានការឯកភាពពីភាគីទាំងពីរ។

**មាត្រា១៩៖** អនុស្សរណៈនៃការយោគយល់គ្នានេះត្រូវបានធ្វើឡើងជាពីរច្បាប់ ជាភាសាខ្មែរ និងភាសាអង់គ្លេស។ អត្ថបទទាំងពីរពីនេះមានតម្លៃស្មើគ្នាតាមផ្លូវច្បាប់។

ថ្ងៃ ព្រហស្បតិ៍ ១៤កើត ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៩

**តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

អនុប្រធានអចិន្ត្រៃយ៍

**ជូ ប៊ុនអេង**

**តំណាងអង្គការសម្ព័ន្ធចាប់ដៃ**

(CHAB DAI COALITION)

តំណាងប្រចាំប្រទេស

**រស់ យ៉េង**